អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦

នៅក្នុងសប្តាហ៍នេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងបើកសិក្ខាសាលាបណ្តុះបណ្តាលសម្រាប់ការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេត។

ប្រធានបទសម្រាប់សិក្ខាសាលានេះរួមមាន៖ ប្រភពនៃនីតិវិធី, ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, ឧត្តមានុវត្តន៍, ឧក្រិដ្ឋកម្មនានា, ការទទួលខុសត្រូវជាបុគ្គល, ការវិភាគលើភស្តុតាង និងការបង្ហាញនៅក្នុងសវនាការ។

គ្រូបណ្តុះបណ្តាលជាតិសម្រាប់សិក្ខាសាលានេះរួមមាន៖ ឯ.ឧ ហ៊ី សុភា រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ឯ.ឧ ហង្ស រ៉ូវ៉ាកែន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និង ឯ.ឧ ហេង ជី អតីតប្រធានសាលាឧទ្ធរណ៍។

គ្រូបណ្តុះបណ្តាលអន្តរជាតិ រួមមាន៖ លោក Luc Côté អតីតប្រធានអយ្យការអមតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាលេអូន, លោក David Tolbert រដ្ឋអាជ្ញារងអមតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី, លោកស្រី Diane Orentlicher សាស្ត្រាចារ្យច្បាប់អន្តរជាតិ, លោក Michael Scharf សាស្ត្រាចារ្យច្បាប់អន្តរជាតិ, លោកស្រី Susana SaCouto នាយិការនៃការិយាល័យសិក្សាស្រាវជ្រាវលើឧក្រិដ្ឋកម្មសង្គ្រាម និងលោកស្រី Kelly Askin មន្ត្រីច្បាប់ជាន់ខ្ពស់មកពីអង្គការ OSJI។

សិក្ខាសាលានេះនឹងត្រូវបានរៀបចំឡើងសម្រាប់រយៈពេលប្រាំថ្ងៃបន្ទាប់នេះ នៅក្នុងសាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

សេចក្តីថ្លែងបើកមួយច្បាប់របស់ប្រធានការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក ត្រូវបានភ្ជាប់មកជាមួយនឹងសារនេះ។

សម្រាប់ព័ត៌មានលម្អិតបន្ថែមទៀតស្តីពីសិក្ខាសាលានេះ សូមទាក់ទងមកកាន់ការិយាល័យផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក

(ទូរសព្ទលេខ: ០១២ ៤៨៨ ១៣៤)